**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# សេចក្តីជូនដំណឹង

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ ឧកញ៉ា លោក លោកស្រី ជាម្ចាស់កន្លែងកែច្នៃបឋមសំបុកត្រចៀកកាំសម្រាប់នាំចេញ និងម្ចាស់ផ្ទះថែរក្សាសត្វត្រចៀកកាំជាលក្ខណៈគ្រួសារ ជ្រាបថា ពិធីសារដើម្បីនាំចេញសំបុកត្រចៀកកាំពីកម្ពុជា ត្រូវបានចុះហត្ថលេខាដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៃព្រះរាជាណាចក្រកម្ពុជា ជាមួយអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមអំពាវនាវដល់ម្ចាស់កន្លែងកែច្នៃបឋមសំបុកត្រចៀកកាំសម្រាប់នាំចេញ និងម្ចាស់ផ្ទះថែរក្សាសត្វត្រចៀកកាំជាលក្ខណៈគ្រួសារដែលមានបំណងនាំចេញសំបុកត្រចៀកកាំទៅកាន់ប្រទេសចិន សូមមកដាក់ពាក្យស្នើសុំនៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ដូចមានគំរូពាក្យស្នើសុំភ្ជាប់មកជាមួយសេចក្តីជូនដំណឹងនេះ)។

បន្ទាប់ពីទទួលបាននូវពាក្យស្នើសុំ អង្គភាពជំនាញនឹងធ្វើការត្រួតពិនិត្យ និងវាយតម្លៃ ដោយអនុលោមតាមបទដ្ឋានបច្ចេកទេសពាក់ព័ន្ធដូចមានកំណត់ក្នុងពិធីសារ និងសម្របសម្រួលជាមួយភាគីគយចិនដើម្បីនាំចេញ។

សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងការដាក់ពាក្យស្នើសុំនេះ  សូមទំនាក់ទំនងតាមរយៈទូរសព្ទលេខ ០៩៣ ២៦៥៥២៦។

ថ្ងៃសុក្រ ៤ រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០២៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំចុះបញ្ជីផ្ទះគ្រងចៀកកាំជាលក្ខណៈគ្រួសារ

ខ្ញុំបាទ□/នាងខ្ញុំ□ឈ្មោះ :..............................................................................................
កាន់អត្តសញ្ញាណប័ណ្ណ / លិខិតឆ្លងដែនលេខ :.....................................ថ្ងៃទី......ខែ..........ឆ្នាំ..............
ជាម្ចាស់ផ្ទះគ្រចៀកកាំ :.................................................................................................
អាសយដ្ឋាន :.................................................................................................
ទូរសព្ទទំនាក់ទំនង :.................................................................................................

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ សំណើសុំការត្រួតពិនិត្យវាយតម្លៃដើម្បីទទួលបានការចុះបញ្ជីផ្ទះគ្រចៀកកាំជាលក្ខណៈគ្រួសារ។
**ឯកសារជូនភ្ជាប់៖**

១. ប្លង់កម្មសិទ្ធិ/ជួល កាន់កាប់អចលនវត្ថុ លេខ..............................ចុះថ្ងៃទី....../....../......
២. អត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែន លេខ..............................ចុះថ្ងៃទី....../....../......
៣. រូបថតផ្ទះគ្រចៀកកាំ(គ្រប់ជ្រុងផ្ទះ) ០៤សន្លឹក

(បណ្ដាឯកសារពាក់ព័ន្ធដទៃទៀតដែលមានប្រសិទ្ធភាពគាំទ្រការវាយតម្លៃ និងប្រគល់ជូនបន្ថែមតាមការចាំបាច់)

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំ មានបំណងថែរក្សាសត្វគ្រចៀកកាំជាលក្ខណៈគ្រួសារ ដែលមានទីតាំងស្ថិតនៅ ភូមិ.....................................ឃុំ/សង្កាត់...................................................ស្រុក/ខណ្ឌ.................................. ខេត្ត/រាជធានី...........................................................។

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ ខែ ឆ្នាំ ស័ក ព.ស.២៥៦...
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២...
ហត្ថលេខា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ.................

## ពាក្យស្នើសុំចុះបញ្ជីកន្លែងកែច្នៃបឋមសំបុកត្រចៀកកាំ

ខ្ញុំបាទ☐/នាងខ្ញុំ☐ឈ្មោះ :....................................................................................................
កាន់អត្តសញ្ញាណប័ណ្ណ / លិខិតឆ្លងដែនលេខ : .......................................ថ្ងៃទី......ខែ.........ឆ្នាំ..............
ជាប្រធានក្រុមហ៊ុន :....................................................................................................
អាសយដ្ឋានក្រុមហ៊ុន :....................................................................................................
ទូរសព្ទទំនាក់ទំនង :....................................................................................................

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ សំណើសុំការត្រួតពិនិត្យវាយតម្លៃដើម្បីទទួលបានការចុះបញ្ជីកន្លែងកែច្នៃបឋមសំបុកត្រចៀកកាំ។
**ឯកសារភ្ជាប់៖**

១. លិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្ម ដែលកំណត់ពីកម្មវត្ថុអាជីវកម្ម លេខ.........ចុះថ្ងៃទី...../....../.........
២. វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម
លេខអត្តសញ្ញាណកម្មសារពើពន្ធ (VAT) លេខ.........ចុះថ្ងៃទី...../....../.........
៣. ប័ណ្ណប៉ាតង់ឆ្នាំចុងក្រោយ (ស្ថិតក្នុងសុពលភាព) លេខ.........ចុះថ្ងៃទី...../....../........
៤. ឯកសារបច្ចេកទេសរបស់ក្រុមហ៊ុនស្តីពីការគ្រប់គ្រងកន្លែងកែច្នៃបឋមសំបុកត្រចៀកកាំ
៥. លិខិតផ្លូវការដទៃដែលពាក់ព័ន្ធ (ប្រសិនបើមាន)៖ ................................................
(បណ្តាឯកសារពាក់ព័ន្ធដទៃទៀតដែលមានប្រសិទ្ធភាពគាំទ្រការវាយតម្លៃ និងប្រគល់ជូនបន្ថែមតាមការចាំបាច់)

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្រុមហ៊ុនយើងខ្ញុំបានសាងសង់ហេដ្ឋារចនាសម្ព័ន្ធ សម្រាប់គាំទ្រការប្រើប្រាស់ក្នុងស្រុក និងការនាំចេញសំបុកត្រចៀកកាំទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ដើម្បីត្រៀមលក្ខណៈក្នុងការចុះត្រួតពិនិត្យវាយតម្លៃពីអគ្គរដ្ឋបាលគយចិន ក្រុមហ៊ុនយើងខ្ញុំ សូមគោរពស្នើសុំមន្ត្រីជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះត្រួតពិនិត្យ និងផ្តល់ដំបូន្មានសម្រាប់ធ្វើការកែលម្អ ឱ្យបានមុនការចុះមកត្រួតពិនិត្យផ្ទៀងផ្ទាត់របស់មន្ត្រីនៃអគ្គរដ្ឋបាលគយចិន។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចចាត់មន្ត្រីធ្វើការពិនិត្យវាយតម្លៃក្រុមហ៊ុនយើងខ្ញុំ ដើម្បីទទួលបានការចុះបញ្ជីកន្លែងកែច្នៃបឋមសំបុកត្រចៀកកាំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ ។

ថ្ងៃ ខែ ឆ្នាំ......... .......ស័ក ព.ស.២៥៦...
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២...
ហត្ថលេខា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ សំណើសុំបញ្ជាក់វិញ្ញាបនបត្របសុព្យាបាលសម្រាប់សំបុកត្រចៀកកាំ ដើម្បីនាំចេញទៅកាន់សាធារណរដ្ឋប្រជាមានិតចិន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំឈ្មោះ...................................... ជាម្ចាស់កន្លែងកែច្នៃបឋមសំបុកត្រចៀកកាំ/ម្ចាស់ថែរក្សាសត្វត្រចៀកកាំជាលក្ខណៈគ្រួសារ កាន់អត្តសញ្ញាប័ណ្ណ ឬលិខិតឆ្លងដែនលេខ.....................................និងលេខទូរសព្ទទំនាក់ទំនង..............................ដែលមានអាសយដ្ឋានបច្ចុប្បន្ននៅភូមិ........................សង្កាត់/ឃុំ .................. ក្រុង/ស្រុក/ខណ្ឌ................................ រាជធានី/ខេត្ត........................................ មានបំណងស្នើសុំបញ្ជាក់វិញ្ញាបនបត្របសុព្យាបាលសម្រាប់សំបុកត្រចៀកកាំចំនួន..............................គីឡូក្រាមក្នុងឆ្នាំ២០...... ដើម្បីនាំចេញទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ដែលព័ត៌មានលម្អិតពាក់ព័ន្ធដូចជូនភ្ជាប់។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ ខែ ឆ្នាំ........ .......ស័ក ព.ស២៥៦...

រាជធានីភ្នំពេញ ថ្ងៃទី..............ខែ...........ឆ្នាំ២០២...

ហត្ថលេខា